# ឌុច លាក់បាំងការពិតនៅពីក្រោយបញ្ហារបស់ខ្លួន

*ដោយសាស្ត្រាចារ្យ ដេវីដ សេវូហ្វាំរ*

*ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត និង វ៉ាន់ថាន់ ពៅដារ៉ា*

*សហព្រះរាជអាជ្ញាអន្តរជាតិលោក វ៉ាលៀម ស្មីត បានបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់លោកនៅក្នុងសវនាការជំនុំជម្រះសេចក្តីប្រឆាំង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានរបស់លោក វ៉ាលៀម ស្មីត ក្រុមមេធាវីការពារក្តីបានក្រោកឡើងនិយាយ ជាដំបូងគឺជនជាប់ចោទ ឌុច និយាយ ហើយបន្ទាប់មកគឺមេធាវីការពារក្តីខ្មែរ លោក កា សាវុធ ឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ខ្លួនទាំងស្រុង ។ ចំណែកឯមេធាវីការពារក្តីអន្តរជាតិ លោក ហ្វ្រង់ស័រ រ៉ូហ្វ នឹងធ្វើបទបង្ហាញពីសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់លោកនៅថ្ងៃព្រហស្បតិ៍ ទី២៦ ខែវិច្ឆិកា ។*

## *សហព្រះរាជអាជ្ញាអន្តរជាតិ លោក វ៉ាលៀម ស្មីត*

*លោក ស្មីត បានចាត់ទុក ឌុច ជាជនដៃដល់ដែលត្រូវទំនួលខុសត្រូវច្រើនបែប តាមមាត្រា ២៩ នៃច្បាប់របស់ អ.វ.ត.ក, បើនិយាយម្យ៉ាងទៀត ជនណាម្នាក់ដែលបានរៀបចំផែនការ ញុះញង់ បញ្ជា ជំនួយ និងជម្រុញ ព្រមទាំងប្រព្រឹត្តខុក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ លោក ស្មីត បានអះអាងថា ឌុច ត្រូវតែបំពេញបំពេញបានតាមបែបនៃការចូលរួមប្រព្រឹត្តទាំងអស់នេះ ដើម្បីបង្កើត និងប្រតិបត្តិការលើមន្ទីរស-២១ ។ លោកក៏បានចោទ ឌុច ថា ជាមេដឹកនាំដែលមិនបានទប់ស្កាត់កុំឲ្យមានឧក្រិដ្ឋកម្មកើតឡើង ឬមិនបានដាក់ទោសទណ្ឌលើអ្នកនៅក្រោមបង្គាប់របស់ខ្លួនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ។ តាមពិត ឌុច បានយកបុគ្គលិកមកធ្វើការផងរ ដើម្បីបំរើគោលបំណងប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងជាក់ច្បាស់ ។*

*បន្ថែមលើនេះទៀត លោក ស្មីត បានលើកឡើងពីការទទួលខុសត្រូវតាមទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមនៅចំពោះមុខចៅក្រម ។ នេះគឺជាបញ្ហាមួយដែលអាចធ្វើឲ្យពន្យាពេលដល់ការចេញសាលក្រមសម្រាប់*

រឿងក្ដីប្រឆាំងនឹង ឌុច ដែលសហព្រះរាជអាជ្ញាអន្តរជាតិត្រូវបង្ខំចិត្តលើកអំណះអំណាងឲ្យអស់ពីសមត្ថ-ភាពក្នុងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោលចុងក្រោយរបស់ខ្លួន ។ លោក ស្មីត បានលើកឡើងថា សហកម្មខក្រិដ្ឋកម្មរួម គ្របសោមបាននូវការទទួលខុសត្រូវសំខាន់ៗរបស់ ឌុច ។ ប្រសិទ្ធភាពរបស់មន្ទីរស-២១ នឹងមិនអាចសម្រេចបានជោគជ័យទេ ប្រសិនបើគ្មានការផ្សារមានផែនការ និងជារួមជាមួយមេដឹកនាំថ្នាក់លើ និងអ្នកក្រោមបង្គាប់ដែល ឌុច បានរៀបចំដឹកនាំក្នុងនាមជាប្រធានគុក ។

បញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌកូនកាត់ និងអន្តរជាតិដទៃៗទៀតក្នុងសម័យកាលទំនើបនេះបានយោងសំដៅលើទម្រង់នៃការទទួលខុសត្រូវដូចគ្នានឹងច្បាប់ អ.វ.ត.ក ដែរ ដែលដូច្នេះហើយទើប លោក ស្មីត ទាញយកនូវអ្វីដែលតុលាការទាំងនោះបានអនុវត្ត គឺសហកម្មខក្រិដ្ឋកម្មរួមយកមកអនុវត្តនៅ អ.វ.ត.ក បានដូចគ្នា ។ លោកបានមានប្រសាសន៍ថា អ្នកធ្វើសេចក្ដីព្រាងច្បាប់ អ.វ.ត.ក មានគោលបំណងចង់ឲ្យច្បាប់នេះក្លាយជាផ្នែកមួយនៃច្បាប់យុត្តិសាស្ត្រពីមុនជាអន្តរជាតិ ដែលត្រូវបានយកមកធ្វើជាគំរូដោយតុលាការផ្សេងៗទៀត ។ ដូច្នេះ ការជំទាស់មិនអនុវត្តសហកម្មខក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវអាចធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានលក្ខណៈខុសប្លែកពីតុលាការដទៃៗទៀត នៅពេលដែលខ្លួនមានបំណងចង់ធ្វើជាតុលាការគំរូនោះ ។

ចក្ខុវិស័យផ្នែកព្រហ្មទណ្ឌទាក់ទិននឹងសហកម្មខក្រិដ្ឋកម្មរួម គឺដើម្បីប្រើប្រាស់ខក្រិដ្ឋកម្មផ្សេងទៀតធ្វើជាមធ្យោបាយក្នុងការសម្រេចបាននូវគោលដៅយុត្តិធម៌ព្រហ្មទណ្ឌ ។ លទ្ធផលគឺអាចជាការប្រព្រឹត្តខក្រិដ្ឋកម្មដែលមានលក្ខណៈកាន់តែធ្ងន់ធ្ងរជាង ខក្រិដ្ឋកម្មដែលព្រឹត្តឡើងតែមួយ ។ លោក ស្មីត បានស្នើយោបល់ថាសហកម្មខក្រិដ្ឋកម្មរួមស្រសោបលើវិសាលភាពនៃខក្រិដ្ឋកម្មរបស់ឌុចបានយ៉ាងល្អឥតខ្ចោះ ។ លោកសហព្រះរាជអាជ្ញា មិនយល់ស្របយ៉ាងច្បាស់ក្រឡែតនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបដិសេធចោលនូវសហកម្មខក្រិដ្ឋកម្មរួម ហើយលោក ស្មីត បានស្នើឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវដាក់ពិរុទ្ធភាពលើ ឌុច តាមទម្រង់នៃសហកម្មខក្រិដ្ឋកម្មរួម ។

លោក ស្មីត បានលើកឡើងថា ទាក់ទិននឹងការប្រព្រឹត្តខក្រិដ្ឋកម្មដោយផ្ទាល់របស់ ឌុច គឺត្រូវបានកំណត់ត្រឹមតែការប្រព្រឹត្តធ្ងន់ធ្ងរចំនួនតូចមួយតែប៉ុណ្ណោះ ។ លោកសហព្រះរាជអាជ្ញាបាននិយាយថា ឌុច គួរតែមានពិរុទ្ធភាពតាមទម្រង់នៃការប្រព្រឹត្តខក្រិដ្ឋកមជាក់ស្ដែងថែមទៀត ។ លោក ស្មីត សន្និដ្ឋានបញ្ចប់ថា សហព្រះរាជអាជ្ញាបានបង្ហាញឲ្យឃើញ ច្បាស់គ្មានអ្វីដែលគួរឲ្យមន្ទិលសង្ស័យពីខក្រិដ្ឋកម្មប្រឆាំងនឹង

មនុស្សជាតិ ការរំលោភធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានពីរប្រភេទទៀតគឺ មនុស្សឃាត និងការ ធ្វើទារុណកម្ម តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

## ការផ្តន្ទាទោស

លោក ស្មីត បានធ្វើសេចក្តីថ្លែងការណ៍ដ៏វែងមួយពីការផ្តន្ទាទោសរបស់ ឌុច ប្រសិនបើ ឌុច ត្រូវបាន រកឃើញថា មានពិរុទ្ធភាពចំពោះបទចោទទាំងអស់នោះ (ឌុច បានទទួលស្គាល់ពិរុទ្ធភាពនោះរួចហើយ) ។ លោកបាននិយាយថា នៅក្នុងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ គ្មានសេចក្តីណែនាំជាក់លាក់ណាមួយ សម្រាប់ផ្តន្ទាទោសឡើយ ។ ដូច្នេះ ចាំបាច់ត្រូវតែពិនិត្យលើគោលការណ៍ផ្តន្ទាទោសរបស់តុលាការដទៃ ផ្សេងទៀតទើបបាន ។ យោងតាមបទដ្ឋានទាំងអស់នោះ ការផ្តន្ទាទោសត្រូវតែឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្ម ។ នៅទីនេះគឺមានភាពធ្ងន់ធ្ងរយ៉ាងច្បាស់លាស់ទាំងក្នុងចំនួន ទាំងក្នុងប្រភេទឧក្រិដ្ឋកម្មដែល ត្រូវបានប្រព្រឹត្តជាប្រចាំ និងជាប្រព័ន្ធនៅមន្ទីរស-២១ ។ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងមានឥទ្ធិពលប៉ះ ពាក់ដល់សតិអារម្មណ៍ និងរូបរាងកាយក្នុងរយៈពេលវែងលើជនរងគ្រោះ និងសាច់ញាតិរបស់ខ្លួន ។ អ្នករស់រានមានជីវិតពីមន្ទីរស-២១ ចំនួនបីរូបដែលបានផ្តល់សក្ខីកម្មនៅក្នុងរឿងក្តីនេះនៅមានអារម្មណ៍ ភ័យតក់ស្លុតជានិច្ចចំពោះភាពជាប់ឃុំឃាំង និងការប្រព្រឹត្តព្រៃផ្សៃមកលើខ្លួន រួមទាំងអារម្មណ៍មិននឹង នរទៀតផង ។ សមាជិកគ្រួសាររបស់អ្នករស់រានមានជីវិត មាននៅគ្រប់ទីកន្លែងជុំវិញពិភពលោកដោយ មានគ្រួសារជាច្រើន ត្រូវបានខ្ចាត់ខ្ចាត់ពីគ្នាដោយ សារតែអ្វីដែលបានកើតឡើងចំពោះសមាជិកគ្រួសារ ជាទីស្រឡាញ់របស់ខ្លួននៅឯមន្ទីរស-២១ ។ ចំពោះអ្នកខ្លះ ការធ្វើអត្តឃាតបានក្លាយជាមធ្យោបាយ តែមួយគត់ដើម្បីដោះស្រាយនូវទុក្ខសោកទាំងនេះ ។ លោក ស្មីត បានជឿជាក់ថា ចំនួនសមាជិកគ្រួសារ នៃជនរងគ្រោះទាំងនោះ មិនអាចដឹងច្បាស់នៅឡើយទេ ប៉ុន្តែ វាប្រាកដជាមានចំនួនដល់ទៅរាប់ម៉ឺននាក់ ឯណោះ ។ ការបាត់បង់មនុស្សទាំងអស់នេះ កំពុងតែធ្វើឲ្យប៉ះពាល់ដល់ជនរងគ្រោះរាប់មិនអស់នៅ ទូទាំងប្រទេស ដោយសារជម្ងឺផ្លូវចិត្ត ។

ទំហំនៃចូលរួមប្រព្រឹត្តរបស់ ឌុច គឺអាស្រ័យលើការពិនិត្យបច្ច័យរបស់តុលាការថាតើ ឌុច បានបង្កការ ឈឺចាប់ដោយផ្ទាល់ដៃ ឬតាមរយៈការងាររបស់អ្នកដទៃដែល ឌុច បានគ្រប់គ្រងក្នុងនាមជាមេដឹកនាំ នៅមន្ទីរស-២១ ។ ប្រសិនបើការប្រព្រឹត្តរបស់ ឌុច កើតឡើងទាំងពីរករណីនោះ ឌុច មានពិរុទ្ធភាព កាន់តែខ្លាំង ។ ប្រសិនបើ ឌុច បានចូលរួមប្រព្រឹត្តអំពើបែបនេះដោយមោះមុតនោះ ការចូលរួមប្រព្រឹត្ត បទឧក្រិដ្ឋរបស់គាត់ មានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងៗ ។ ម្យ៉ាងទៀត ប្រសិនបើ ឌុច ប្រព្រឹត្តអំពើ

បែបនោះដោយស្ម័គ្រចិត្ត និងមានការគិតគូទុកជាមុនច្បាស់លាស់ នោះការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋរបស់គាត់នឹងឈានដល់កម្រិតកំពូល ។ តាមពិត ឌុច បាននៅជាប់ជាមួយបក្សកុម្មុយនីស្តកម្ពុជាពេញមួយអំឡុងពេលដែលអំពើហិង្សាបានកើតឡើង ។ លោក ស្មីត បានលើកឡើងថា ឌុច គឺជាមេដឹកនាំដែលមានសមត្ថភាព និងរីករាយនឹងការប្រែក្លាយបុគ្គលិករបស់ខ្លួនឲ្យទៅជាឃាតករសម្លាប់មនុស្ស ។ ឌុច បានធ្វើការងាររបស់ខ្លួនស្ទាត់ជំនាញគ្រប់បែបយ៉ាង ។ ក្នុងនាមជាប្រធានមន្ទីរស-២១ ឌុច មានការទទួលខុសត្រូវខ្ពស់លើការធ្វើទារុណ្ណកម្មក្នុងទ្រង់ទ្រាយធំ ។ មានជនរងគ្រោះរាប់ម៉ឺននាក់ត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម និងសម្លាប់នៅគុកទួលស្លែង ។ ឌុច បានដើរត្រួតពិនិត្យមើលបន្ទប់សួរចម្លើយ ទាត់ធាក់អ្នកទោសផ្ទាល់ និងបង្ខំឲ្យអ្នកទោសវាយប្រតប់គ្នាទៀតផង ។ ឌុច គឺជាឧបករណ៍ដ៏សំខាន់មួយនៅក្នុងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីវែកមុខ និងសម្លាប់អ្នកដែលសន្មត់ថា ជាខ្មាំង ។ ជាក់ស្តែង អ្វីដែល ឌុច បានប្រព្រឹត្ត ពិតជាខុសប្លែកពីគេពីឯងទាំងអស់នៅលើលោកនេះ បើនិយាយពីវិសាលភាព និងភាពសាហាវឃោរឃៅនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ។

លោក ស្មីត បានក្រើនរំឭកដល់អង្គជំនុំជម្រះថា ឌុច គឺជាមនុស្សដែលបានរៀនសូត្រជ្រៅជ្រះ មានប្រាជ្ញាឈ្លាសវៃ និងជាមនុស្សមានហេតុផល ។ ឌុច បានសម្រេចជ្រើសរើសធ្វើជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ជាជាងដកខ្លួនចេញពីបក្សនេះ ។ ក្នុងនាមជាប្រធានមន្ទីរម-១៣ អស់រយៈពេល ៤ឆ្នាំមុនពេល ប៉ុល ពត ឡើងគ្រប់គ្រងប្រទេសកម្ពុជា ឌុច បានដឹងយ៉ាងច្បាស់ថា ការងារដែលរំពឹងឲ្យខ្លួនធ្វើ គឺការចាប់ខ្លួន ឃុំឃាំង សួរចម្លើយ ធ្វើទារុណ្ណកម្ម និងសម្លាប់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាក់ស្តែង ឌុច បានធ្វើទារុណ្ណកម្មដោយផ្ទាល់ជាច្រើនលើកមកហើយ ក្នុងអំឡុងពេលបួនឆ្នាំនោះ ។

## ស្ថានទម្ងន់ទោស

ក្រោយមកលោក ស្មីត បានបន្តលើកឡើងពីស្ថានទម្ងន់ទោសដែលគួរតែតម្រង់ទិសសម្រាប់ការពិចារណារបស់ចៅក្រមលើការផ្តន្ទាទោសលើ ឌុច ។ ទីមួយ អំណាចរបស់ ឌុច នៅមន្ទីរស-២១មិនមែនជាស្ថានទម្ងន់ទោសទេ ប៉ុន្តែរបៀបដែល ឌុច ប្រើប្រាស់អំណាចរបស់ខ្លួនទើបជាស្ថានទម្ងន់ទោស ។ ឌុច គួរតែការពារសិទ្ធិរបស់អ្នកជាប់ឃុំឃាំងនៅទីនោះ ប៉ុន្តែ បែរជាមិនបានធ្វើយ៉ាងដូច្នេះទៅវិញ ។

តាមពិត ឌុច បានប្រព្រឹត្តផ្ទុយពីនេះ ។ ឌុច មិនដែលបានធ្វើខ្លួនដូចជាអ្នកដែលមានកាតព្វកិច្ចការពារសុខុមាលភាពរបស់អ្នកទោសអ្វីសោះឡើយ ។

ទីពីរ លោក ស្មិត បានអះអាងថា ការបង្កនូវភាពឈឺចាប់ និងទុក្ខលំបាកវេទនាមិនធម្មតាលើជនរងគ្រោះ គឺជាស្ថានទម្ងន់ទោសយ៉ាងពិតប្រាកដ ។ អ្វីដែល ឌុច បានគ្រប់គ្រង គឺសុទ្ធតែមានលក្ខណៈសាហាវព្រៃផ្សៃ រីករាយនឹងការឈឺចាប់របស់អ្នកដទៃ និងគ្មានមេត្តាធម៌ ។ ការចងក្រងនូវភាពព្រៃផ្សៃនៅមន្ទីរ ស-២១ គឺពិតជាមានលក្ខណៈអាក្រក់ក្រៃលែង ហើយលោក ស្មិត ក៏បន្តអធិប្បាយពីភាពព្រៃផ្សៃនោះមានលក្ខណៈបែបណាបន្តទៀត ។ លោកបាននិយាយថា ភាពព្រឺខ្លាច តក់ស្លុត ភាពភិតភ័យ គឺមានលក្ខណៈហួសពីការស្មានដល់របស់យើងឆ្ងាយណាស់ ។ អ្នកទោសបានមើលឃើញនូវអ្វីដែលនឹងកើតឡើងនៅថ្ងៃខាងមុខពីដោតវាសនារបស់គេ ។ លោក ស្មិត បានលើកឡើងបន្ថែមថា "ចូរគិតពីអារម្មណ៍ដែលអ្នកទោសទាំងនោះមាននៅពេលដែលអ្នកទោសនៅជាមួយគ្នាបានបាត់ខ្លួន ហើយចំណែកឯអ្នកទោសឯទៀតរង់ចាំតែថ្ងៃហៅឈ្មោះរបស់ខ្លួនតែប៉ុណ្ណោះ ។ ចូរគិតមើលថា តើមានអ្នកទោសប៉ុន្មាននាក់ដែលប៉ុនប៉ងធ្វើអត្តឃាត" ។

លោក ស្មិត បានរៀបរាប់ពីភាពដែលមិនអាចការពារខ្លួនបានរបស់ជនរងគ្រោះនៅឯវាលពិឃាត ។ លោកបានលើកឡើងថា ស្ថានទម្ងន់ទោសទាំងបីនេះ គឺជាប់ពាក់ព័ន្ធផ្ទាល់ និងត្រូវ យកមកពិចារណាក្នុងការផ្តន្ទាទោសលើ ឌុច ។

## ស្ថានសម្រាលទោស

បន្ទាប់មកទៀត លោក ស្មិត បានទាញយកចំណាប់អារម្មណ៍របស់លោកដោយផ្តោតមកលើស្ថានសម្រាលទោសសម្រាប់ការផ្តន្ទាទោស ។ ទាក់ទិននឹងការបន្ទិតបន្ទំ ភស្តុតាងមិនបានគាំទ្រដល់ការអះអាងរបស់ ឌុច ដែលថា គាត់ស្អប់ការងាររបស់ខ្លួននោះឡើយ ។ ឌុច គឺជាមនុស្សដែលបង្កឲ្យមានភាពព្រឺខ្លាច មិនមែនជាជនរងគ្រោះនៃភាពព្រឺខ្លាចនោះទេ ។ លោក ស្មិត អះអាងថា មេធាវីការពារក្តីមិនបានបង្ហាញឲ្យឃើញថា ឌុច បានទទួលរងនូវភាពព្រឺខ្លាចដែលចាប់ផ្តើមលុកលុយចូលក្នុងប្រទេសក្នុងឆ្នាំ១៩៧៨ នោះទេ ។ លោកបន្តថា ដូចលោកស្រី អាលីហ្សាបែត បេកឌីបានសរសេរអីចឹង ឌុច គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលជាមេដឹកនាំសំខាន់បំផុតរបស់ប្រទេសនាអំឡុងពេលនោះ ។ឌុច បាន

ធ្វើឲ្យភាពព្រឺខ្លាចរីកសាយភាយទូទាំងប្រទេសកម្ពុជា ក្នុងឋានៈជាប្រធានមន្ទីរស-២១ ។ ឌុច បានច្នៃបង្កើតម៉ាស៊ីននៃភាពព្រឺខ្លាច និងជាអ្នកចូលប្រឡូកដែលមានឆន្ទះមោះមុតបំផុត ។

ការការពារខ្លួនឲ្យរួចផុតពីបញ្ជាថ្នាក់លើ ដែលចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក តម្រូវថាអ្នកនៅក្រោមបង្គាប់ដែលយកការការពារខ្លួនមកធ្វើជាស្ថានសម្រាលទោស ត្រូវតែបញ្ជាក់ឲ្យច្បាស់ថាបញ្ជាទាំងនោះបានជះឥទ្ធិពលលើការប្រព្រឹត្តរបស់ខ្លួន ។ ប៉ុន្តែការការពារខ្លួនបែបនេះ អាចបរាជ័យប្រសិនបើជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយពុំមានការបញ្ជាជាក់លាក់ណាមួយ ។ តាមពិត ឌុច មានមហិច្ឆតាចង់ធ្វើបដិវត្តន៍ និងកម្មេចខ្មាំងរបស់បដិវត្ត ជាជាងគ្រាន់តែគោរពតាមបញ្ជាតែមួយមុខ ។ ជាសរុប ការបង្ខិតបង្ខំ និងការធ្វើតាមបញ្ជារបស់ថ្នាក់លើមិនអាចចាត់ទុកថាមានជាប់ ពាក់ព័ន្ធជាមួយការបង្ខិតបង្ខំឡើយ ដូច្នេះករណីទាំងពីរនេះមិនគួរចាត់ទុកជាស្ថានសម្រាលទោសឡើយ ។

យោងតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ការសហការនឹងតុលាការគឺជាស្ថានសម្រាលទោស ។ ការសាកល្បងអាស្រ័យលើបរិមាណ និងគុណភាពនៃព័ត៌មានដែលបានផ្តល់ជូន ហើយត្រូវតែផ្តល់ឲ្យដោយខ្លួនឯងផ្ទាល់ដោយគ្មានគំនិតគិតពីប្រយោជន៍ដែលនឹងទទួលបានមកវិញ ។ ការសហការមុនៗក៏មានសារៈសំខាន់ដូចជាការសហការនៅក្នុងដំណើរការស៊ើបអង្កេត សម្រាប់ការជំនុំជម្រះរឿងក្តីផ្សេងៗទៀតដែរ ។ ប្រសិនបើព័ត៌មានដែលផ្តល់ជូនមានកំរិតណាមួយ ឬមិនពិតទាំងស្រុងនោះ ការសហការនឹងមិនត្រូវបានសន្មត់ថា គ្រប់គ្រាន់នោះឡើយ ។ ជាក់ស្តែង ឌុច បានជ្រើសយកជម្រើសមិនព្រមចុះចាញ់ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៩ ។ រយៈកាល២០ឆ្នាំដែល ឌុច នៅជាជនរត់គេចខ្លួននោះ តាមពិតទៅគឺគាត់បានធ្វើការរួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យដ៏ស្មោះស្ម័គ្រម្នាក់ អស់រយៈពេល១៥ឆ្នាំឯណោះ ។ ឌុច បានដូរឈ្មោះ និងមិនបានលាតត្រដាងពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងមន្ទីរស-២១ទេ ។ នៅពេលដែលអ្នកថតរូប នីក ឌុនឡុប (Nic Dunlop) បានតាមរកគាត់ឃើញ ទើប ឌុច ដឹងថាខ្លួនថា ខ្លួនមិនអាចលាក់ការពិតតទៅទៀតបាន ។ ឌុច ប្រហែលជាមិនត្រូវបានចាប់ខ្លួន និងឃុំឃាំងទេ ប្រសិនបើលោក ឌុនឡុប មិនតាមរក ឌុច ឲ្យបានជាប់លាប់នោះ ។

តាមពិត ឌុច ទើបតែបានផ្តល់ភស្តុតាងនាពេលថ្មីៗទាក់ទិននឹងបក្សកុម្មុនីស្តកម្ពុជា និងព័ត៌មានទាក់ទងនឹងមេដឹកនាំជាន់ខ្ពស់ដែលទទួលការចោទប្រកាន់ ។ យ៉ាងណាមិញ លោក ស្មីត បានអះអាងថា ឌុច បានទទួលស្គាល់ការពិតដែលទាក់ទិននឹងការប្រព្រឹត្តរបស់ខ្លួនតែមួយផ្នែកណាប៉ុណ្ណោះទេ ។ ឌុច បានត្រឹមតែសារភាព

ថា «ខ្ញុំបានធ្វើរឿងអាក្រក់ៗជាច្រើន ប៉ុន្តែវាមិនមែនជាកំហុសរបស់ខ្ញុំទេ, វាគឺជាកំហុស របស់ថ្នាក់លើខ្ញុំ» ។

## លោក ស្មីត បានវាយប្រហារចំនឹងយុត្តិសាស្ត្រការពារក្តី

បន្ថែមលើនេះទៀត លោក ស្មីត បានពន្យល់ថា យុត្តិសាស្ត្រការពារក្តីនៅក្នុងតុលាការ គឺព្យាយាមកំរិតកិច្ចខិតខំប្រឹងប្រែងរបស់តុលាការក្នុងការពិនិត្យលើអង្គហេតុ ។
ឥទ្ធិពលជាបន្ថែមនៃកិច្ចការប្រឈមរបស់មេធាវីការពារក្តី គឺព្យាយាមកាត់បន្ថយនូវការជះឥទ្ធិពលនៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ ឌុច ផ្ទាល់លើឧក្រិដ្ឋកម្មទាំងនោះ ។ មេធាវីការពារក្តីបានបញ្ឈាក់ពីភស្តុតាងដ៏តិចតួចដែលអាចភ្ជាប់ ឌុច ទៅនឹងដែនយុត្តាធិការលើបុគ្គល ដែលត្រូវយកមកកាត់ទោសដោយអនុលោមតាមមាត្រា ១នៃច្បាប់ អ.វ.ត.ក ។ មេធាវីការពារក្តី បានជំទាស់នឹងភស្តុតាងទាំងឡាយណាដែលបានលើកឡើងទាក់ទិននឹងអាកាប្បកិរិយារបស់ ឌុច នៅមន្ទីរម-១៣ មុនការកើតឡើងពីដែនយុត្តធិការលើពេលវេលារបស់តុលាការ ។ ការជំទាស់នេះ បានរារាំងតុលាការមិនឲ្យធ្វើការពិនិត្យពិច័យលើភស្តុតាងដែលទាក់ទិននឹងបុគ្គលិកលក្ខណៈរបស់ ឌុច ជាអ្នកសម្លាប់មនុស្ស ។ ផ្ទុយទៅវិញ មេធាវីការពារក្តីមានបំណងចង់ឲ្យតុលាការស្តាប់ឮពីអាកាប្បកិរិយាល្អៗរបស់ ឌុច ដែលនៅជាកូនសិស្សវ័យក្មេងម្នាក់ មុនពេលអំពើសាហាវឃោរឃៅបានកើតឡើងក្នុងរវាងឆ្នាំ១៩៧៥ និង១៩៧៩ យូរយារណាស់ ។ ជាមួយគ្នានេះ មេធាវីការពារក្តីក៏បានជំទាស់នឹងសេចក្តីសង្ខេបលម្អិតរបស់សាក្សី ថែមទៀតដែលនេះគឺជាយុទ្ធសាស្ត្រមួយដែលរៀបចំឡើង ដើម្បីធ្វើឲ្យភស្តុតាងជាលាយលក្ខណ៍អក្សរដ៏សន្ធឹកសណ្ធាប់កាន់តែមានតិចតួចទៅៗសម្រាប់តុលាការប្រើប្រាស់ ។ ចៅក្រមត្រូវការជាចាំបាច់នូវសេចក្តីសង្ខេបទាំងនេះដើម្បីយកមកធ្វើជាគោល ក្នុងការស្វែងយល់អំពីបញ្ហាសំខាន់ដែលមាននៅក្នុងរឿងក្តី ។ ក៏ប៉ុន្តែ គោលបំណងរបស់មេធាវីការពារក្តីគឺច្បាស់ណាស់ គឺថាធ្វើឲ្យកាន់តែមានភាពស្រពិចស្រពិល ។

មេធាវីការពារក្តី បានបដិសេធចំពោះបញ្ជីសាក្សីបម្រុងដែលអាចបំពេញនូវការខ្វះចន្លោះ ប្រសិនបើសាក្សីទាំងនោះ ទទួលរងនូវបញ្ហាបាត់បង់ការចងចាំ ឬក៏ប្រឈមនឹងបញ្ហាលំបាកក្នុងការរំឭកពីរឿងរ៉ាវឡើងវិញ ។ លោក ស្មីត បានចាត់ទុកសាក្សីបម្រុងជាការណ៍សំខាន់ ពីព្រោះអង្គជំនុំជម្រះបានហាមប្រាមមិនឲ្យសហព្រះរាជអាជ្ញាជួបជាមួយសាក្សីជាមុនទេ ។ ដោយសារតែសាក្សីភាគច្រើនគឺជាអតីតបុគ្គលិកមន្ទីរស-២១ វាមានការលំបាកក្នុងការស្វែងយល់ថា តើបុគ្គលិកម្នាក់ៗនឹងកុហក់ ឬកំណត់យកតែព័ត៌មាន

ខ្លះៗ ដែលត្រូវបានស្នើសុំឲ្យនិយាយទាក់ទិននឹងពិរុទ្ធភាពផ្ទាល់ខ្លួន និងភាពអាម៉ាស់នោះ ។ ចំណុចនេះបានបង្ហាញឲ្យឃើញថា ពិតជាត្រឹមត្រូវក្នុងអំឡុងពេលសវនាការ ពីព្រោះឃើញមានភាពស្ទាក់ស្ទើរក្នុងការនិយាយជាចំហរ ។ នៅពេលដែលមេធាវីការពារក្តីបានធ្វើការណែនាំយ៉ាងស្វាហាប់ដល់សាក្សី ដែលធ្លាប់ធ្វើជាអ្នកសួរចម្លើយនៅមន្ទីរស-២១ថា ពួកគេអាចនឹងកាត់ទោសដោយតុលាការជាតិនោះ មេធាវីការពារក្តីបានបញ្ជូនសារមួយដល់សាក្សីស្រដៀងៗគ្នានេះថា អ្នកទាំងអស់នោះប្រហែលជានឹងត្រូវកាត់ទោសដោយតុលាការជាតិ ។ មេធាវីការពារក្តី បានបង្កនូវភាពភ័យខ្លាចដល់សាក្សីគ្រប់រូបដែលធ្លាប់ធ្វើការនៅមន្ទីរស-២១ ។ យុទ្ធសាស្ត្រនេះមិនបានជម្រុញឲ្យសាក្សីនិយាយការពិតនោះទេ ។ ជាក់ស្តែង មេធាវីការពារក្តី រីករាយណាស់ដោយឃើញសាក្សីមិនអាចនិយាយការពិតបាន ។ ជាចុងក្រោយ មេធាវីការពារក្តីបានព្យាយាមដាក់កំរិតលើឯកសារដែលត្រូវដាក់ជូនទៅតុលាការ រួមទាំងឯកសារដែលទាក់ទងនឹងការស្រាវជ្រាវស្តីពីការកកើតឡើងនូវជម្លោះប្រដាប់អាវុធអន្តរជាតិ របស់អ្នកជំនាញ ក្រេក អែតចឹសាន់ (Craig Etcheson) ជាដើម ។

ដូច្នេះឃើញថា ម្យ៉ាង ឌុច បានផ្តល់ភស្តុតាងទាក់ទិននឹងបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់បានជួយផ្តល់ព័ត៌មានដល់តុលាការដោយស្ម័គ្រចិត្ត ។ ម្យ៉ាងវិញទៀត ឌុច មិនបានសហការក្នុងការរៀបរាប់ពីតួនាទីរបស់ខ្លួននៅមន្ទីរស-២១ឡើយ ។ ឌុច បាននិយាយការពិតតែនៅពេលដែលការពិតនោះវាមានការលំបាកនឹងបិទបាំងការពិតតែប៉ុណ្ណោះ ។ លោក ស្មីត បាននិយាយថា “អ្នកមិនអាចជំទាស់នឹងដំណើរការជំនុំជម្រះទាំងស្រុងបាន ហើយក្រោយមកបែរជាអះអាងថា អ្នកបានសហការជាមួយតុលាការវិញ” ។

ទាក់ទិននឹងការទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច លោក ស្មីត បានចាត់ទុកថា នៅ មានកំរិតនៅឡើយ បើមើលពីចរិកលក្ខណៈនោះ ។ នៅពេលដែលនិយាយពីការជាប់ពាក់ព័ន្ធរបស់ខ្លួន នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឌុច គឺតែងតែមានលក្ខណៈរឹងរូសជានិច្ចនៅក្នុងអង្គសវនាការ ។ ឌុច បានអះអាងថា ខ្លួនត្រូវបានបង្ខំឲ្យធ្វើទារុណ្ឌកម្ម និងសម្លាប់មនុស្ស ។ លោក ស្មីត បានស្នើឡើងថា ឌុច ត្រូវតែទទួលស្គាល់និងហ៊ានប្រឈមនឹងការពិតដែលថា ខ្លួនមានឆន្ទះមោះមុតក្នុងការបម្រើបដិវត្តន៍ ។ ឌុច នៅមិនទាន់ទទួលស្គាល់ការទទួលខុសត្រូវឲ្យបានពេញលេញ លើឧក្រិដ្ឋកម្មទាំងអស់នៅចំពោះមុខតុលាការនេះនៅឡើយ ។ វិប្បដិសារីរបស់ ឌុច នៅមានកម្រិត ដោយសារតែការបដិសេធចំពោះការទទួលខុសត្រូវរបស់ខ្លួន ។ ឌុច មិនមានសមត្ថភាពក្នុងការធ្វើឲ្យអ្នកដទៃចាប់អារម្មណ៍ខ្លាំងលើចំណុចនេះទេ ។

តើការបន្ធូរបន្ថយទោសសម្រាប់ ឌុច អាចជួយឲ្យមានការផ្សះផ្សាជាតិដែរឬទេ? លោក ស្មឹត បាននិយាយថា នេះគឺជាការពិចារណាដ៏ត្រឹមត្រូវមួយ ក៏ប៉ុន្តែអាកប្បកិរិយារបស់ ឌុច មិនបានជួយឲ្យមានការផ្សះផ្សាជាតិជាដុំកំភួនឡើយ ។ គោលបំណងរបស់តុលាការ គឺដើម្បីបញ្ចប់វប្បធម៌នៃនិទ្ទណ្ឌភាព (ការរួចទោស) ។ ការបន្ធូរបន្ថយទោសកាន់តែខ្លាំងអាចនឹងទទើសទទែង ហើយមិនជួយអ្វីទាំងអស់ដល់ការផ្សះផ្សាជាតិ ។ ការផ្សះផ្សាជាតិ គឺជាលទ្ធផលមួយដែលនឹងសម្រេចដោយតុលាការ ក៏ប៉ុន្តែមិនមែនជាគោលបំណងរបស់តុលាការនេះទេ ។ ការទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច មិនអាចមានឥទ្ធិពលប៉ះពាល់ដល់សន្តិភាពនៅក្នុងប្រទេសឡើយ ។ ឌុច ខកខានមិនបានបញ្ជាក់ឲ្យឃើញថា ការផ្តន្ទាទោសស្រាលជាងនេះនឹងជាប្រយោជន៍ដល់ការផ្សះផ្សាជាតិ ។ លោក ស្មឹត បាននិយាយថា “មនុស្សជាតិ ត្រូវបានបង្កើតឡើងទាំងស្រុងដោយមានការដាក់ទណ្ឌកម្មលើអ្នកដែលរំលោភលើភាពជាមនុស្សជាតិរបស់ខ្លួនឯង” ។ “វាទាមទារឲ្យមានសកម្មភាពកាន់តែច្រើនជាងនេះក្នុងការជម្រុញឲ្យមាន ការផ្សះផ្សា ជាជាងការផ្តន្ទាទោសស្រាលដែលមិនសមមាត្រ” ។

## លោក ស្មឹត ស្នើសុំឲ្យផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ៤០ឆ្នាំ

លោក ស្មឹត បាននិយាយគាំទ្រ ឌុច ដោយគិតដល់រយៈពេលដែល ឌុច ជាប់ឃុំឃាំងក្រោមយុត្តាធិការរបស់តុលាការយោធាកម្ពុជាមុននឹងមកដល់ អ.វ.ត.ក ។ ការឃុំឃាំងដែលអូសបន្លាយពេលវែងបែបនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ ។ លោក បានស្នើជាយោបល់ថា “នៅទីនេះ ការប្រតិបត្តិតាមច្បាប់ត្រូវតែអនុវត្ត” ។ នៅពេលដែលជនត្រូវចោទមិនត្រូវ បានធ្វើការកាត់ទោសក្នុងរយៈពេលសមហេតុផលមួយនោះទេ ការរំលោភបំពានលើច្បាប់បែបនេះ ត្រូវតែធ្វើការដោះស្រាយ ។ លោក ស្មឹត បានផ្តល់យោបល់ថា បើពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មក្នុងរឿងក្តីនេះ អង្គជំនុំជម្រះគួរតែចាប់ផ្តើមគិតពីការផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ អង្គជំនុំជម្រះគួរតែពិចារណាលើការរំលោភបំពាននេះ ។ ការប្រព្រឹត្តល្អនឹងត្រូវទទួលបានការបន្ធូរបន្ថយទោសពីការជាប់ពន្ធនាគារអស់មួយជីវិត មកត្រឹមការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារដោយមានពេលកំណត់ច្បាស់លាស់មួយវិញ ។

លោក ស្មឹត បានអះអាងថា ឌុច បានប្រឈមមុខនឹងការជំនុំជម្រះប្រកបដោយយុត្តិធម៌ តាមរយៈចៅក្រមដែលមានឯករាជ្យ និងមិនលម្អៀង ។ ឌុច គួរតែត្រូវបានផ្តន្ទាទោសចំពោះតែឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តតែប៉ុណ្ណោះ ។ នៅមន្ទីរស-២១ អ្នកទោសមិនដែលទទួលបានយុត្តិធម៌បែបនេះទេ ។ ឌុច

បានខិតខំធ្វើយ៉ាងណាឲ្យអ្នកទោសទាំងអស់ត្រូវបានចាត់ទុកដូចជាសត្វធាតុ ។ គ្មានអ្វីដែលអាចយកមកថ្លឹងថ្លែងពីភាពសាហាវឃោរឃៅនៅមន្ទីរស-២១បានទេ ។ ឌុច បានធ្វើការដោយមិនចេះហត់ហើយក្នុងការវែកមុខចាប់ខ្លួន និង«កម្ទេច»ខ្មាំង ។ ឌុច បានសម្តែងការសុំទោសម្តងហើយម្តងទៀត និងស្រក់ទឹកភ្នែកនៅជើងឯក ។ លោក ស្មីត បានទទួលស្គាល់ពីការទទួលយកកំហុសរបស់ ឌុច ។ ប៉ុន្តែ លោកមិនបានឃើញពីវិប្បដិសារីរបស់ ឌុច ឡើយនៅពេលដែល ឌុច បានបដិសេធចំពោះការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មយ៉ាងសកម្មរបស់ខ្លួន ។ ឲ្យតែអាចធ្វើទៅបាន ឌុច តែងតែព្យាយាមបន្ថយតួនាទីរបស់ខ្លួនមកនៅទាបដោយសំអាងថា ការសម្ងាត់ និងភាពព្រឺខ្លាចបានរួមរឹតជាប់ខ្លួន ។ លោក ស្មីត បានស្នើថាអង្គជំនុំជម្រះមិនត្រូវអនុញ្ញាតឲ្យ ឌុច យកសេចក្តីអះអាងមិនពិតមកបិទបាំងដើម្បីការពារខ្លួនឡើយ ។ ឌុច គឺជាមនុស្សម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែលមានភាពស្មោះត្រង់ និងការលះបង់ខ្ពស់ ។ លោក ស្មីត បានស្រង់ពាក្យសម្តីរបស់លោកព្រះរាជអាជ្ញាជាតិអង់គ្លេស វីលៀម ហូខ្រេស នៅឯតុលាការ ណួរឹមប៊ឺក ដែលនិយាយថា «ចំណុចនេះដែលគួរត្រូវពិចារណាគឺ នៅពេលដែលបុគ្គលម្នាក់ត្រូវតែបដិសេធមិនគោរពតាមមេដឹកនាំរបស់ខ្លួន ពីព្រោះបុគ្គលនោះគោរពតាមមនសិការរបស់ខ្លួនឯង» ។ ឌុច មិនព្រមផ្តល់ចម្លើយទៅតាមមនិសការរបស់ខ្លួនឡើយ ។ ឌុច បានលះបង់ចោលនូវសេចក្តីគោរពចំពោះជីវិតមនុស្សដោយចេតនា និងពេញចិត្ត ។ ឌុច មានជម្រើសមួយគឺ រំលោភបំពានលើអំណាចឬមនសិការរបស់ខ្លួន ប៉ុន្តែ ឌុច ជ្រើសរើសយកការរំលោភបំពានលើអំណាច ។

លោក ស្មីត ជឿជាក់ថា ឌុច សមនឹងទទួលបានការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ប៉ុន្តែការផ្តន្ទាទោសបែបនេះ ត្រូវតែបន្ធូរបន្ថយមកត្រឹមការជាប់ពន្ធនាគារដែលមានរយៈពេលកំណត់ជាក់លាក់មួយវិញ ។ លោកបានស្នើសុំឲ្យផ្លាស់ប្តូរការផ្តន្ទាទោសមកត្រឹម ៤៥ឆ្នាំ ដើម្បីបង្ហាញពីរយៈពេលដែល ឌុច ស្ថិតនៅក្រោមការឃុំឃាំងរបស់តុលាការយោធា និងដើម្បីធ្វើជាដំណោះស្រាយបន្ថែមមួយសម្រាប់ការជាប់ឃុំឃាំងដោយមិនមានការកាត់ទោសត្រឹមត្រូវ ហើយផ្ទុយពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ លោក ស្មីត បានស្នើសុំបន្តឲ្យមានការសម្រាលទោសរយៈពេល ៥ឆ្នាំទៀត សម្រាប់ការទទួលស្គាល់ការសហការជាទូទៅ វិប្បដិសារីដែលមានលក្ខខ័ណ្ឌ និងការសុំទោសរបស់ ឌុច ព្រមទាំងឥទ្ធិពលដែលអាចមានលើការផ្សះផ្សាជាតិ ។ ដូច្នេះ លោក ស្មីត ស្នើសុំការផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល ៤០ឆ្នាំ ។

លោក ស្មីត បានបញ្ចប់សេចក្តីសន្និដ្ឋានដោយនិយាយថា សូមអ្នកទាំងអស់គ្នាគិតដល់ការសុបន្តិ និងឱកាស ដែលត្រូវបានបដិសេធដោយសារតែឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ។ ក្រុមគ្រួសាររបស់ជនរងគ្រោះនៅ ទទួលរងទុក្ខលំបាកវេទនានៅឡើយ ។ លោក ស្មីត បាននិយាយថា "អង្គជំនុំជម្រះនេះត្រូវតែនិយាយ ជំនួសមុខឲ្យមនុស្សជាតិ ដែលឧក្រិដ្ឋកម្មបែបនេះនឹងមិនត្រូវបានប្រព្រឹត្តឡើងជាថ្មីម្តងទៀតនោះទេ" ។ "សូមឲ្យការវិនិច្ឆ័យរបស់ចៅក្រមប្រកបដោយយុត្តិធម៌ និងដាក់ឲ្យមានការទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តលើមនុស្សចំនួន ១២,០០០នាក់នេះផង ។ លោក លោកស្រីចៅក្រមមិនមែនដកហូត ភាពជាមនុស្សជាតិរបស់ ឌុច ទេ គឺលោក លោកស្រីកំពុងតែផ្តល់ភាពជាមនុស្សជាតិជូនជនរងគ្រោះនៅ មន្ទីរស-២១តែប៉ុណ្ណោះ" ។

## ឌុច និយាយ

ឌុច ដែលមិនហ៊ានមើលទៅកាន់លោក ស្មីត ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ បានអាន សេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួនដោយងាកមុខទៅកាន់ចៅក្រម និងប្រជាជនកម្ពុជាដ៏ច្រើនកុះករនៅក្នុង សាលសវនាការ ។ ឌុច ផ្តោតស្ទើរតែទាំងស្រុងលើគោលនយោបាយសម្លាប់មនុស្សដែលចោទថាខ្លាំង របស់បក្សកុម្មុយនីស ហើយព្យាយាមគម្លាតខ្លួនចេញពីការចូលរួមធ្វើសេចក្តីសម្រេចដែលឈានទៅរក ការចេញជាគោលនយោបាយ ។ ទាំង ឌុច ទាំងមេធាវីការពារក្តីជាតិលោក ការ សាវុត្ថ បានលើកឡើង ជ្រាំដែលៗដល់ការអនុវត្តន៍ការ "ការកម្ទេច" នៅឯមន្ទីរស-២១ និងនៅតាមទីកន្លែងផ្សេងទៀតក្នុង ប្រទេសកម្ពុជាក្នុងអំឡុងនៃរបប ប៉ុល ពត ។ អ្នកទាំងពីរបានឈប់ប្រើប្រាស់ពាក្យប្រមាថមើលងាយ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រនៃការប្រព្រឹត្តឲ្យមានលក្ខណៈមិនមែនជាមនុស្ស របស់ខ្មែរក្រហមនៅក្នុង បន្ទប់តុលាការ ហើយបែរមកប្រើពាក្យ "ការធ្វើឃាត" ឬ "ការសម្លាប់"វិញ ។ វាហាក់បីដូចជាចម្លែក ដែលថា ពាក្យពេចន៍ដែលមេដឹកនាំខ្មែរក្រហមចង់ឲ្យយើងយកមកប្រើប្រាស់ ឲ្យស្របទៅតាមការប្រើ ប្រាស់របស់ខ្លួនក្នុងអំឡុងឆ្នាំ១៩៧០នោះ បានបង្កឲ្យមានផលប៉ះពាល់ម្តងហើយម្តងទៀតនៅក្នុងដំណើរ ការនីតិវិធីរបស់តុលាការ ។

ឌុច បានរៀបរាប់លម្អិតគួរសម អំពីរបៀបដែលបក្សកុម្មុយនីស្តកម្ពុជា បង្កើតគោលនយោបាយ សម្លាប់មនុស្សក្នុងគោលបំណងការពារបក្សខ្លួនឯង ហើយនិងរបៀបបោសសម្អាតខ្មាំងផ្ទៃក្នុងដែលក្លាយ ជាដំណើរប្រតិបត្តិការគំរូតាំងពីដំបូង ។ ឌុច ទទួលស្គាល់ថា មុនឆ្នាំ១៩៧៥ គាត់បានលង់ខ្លួនយ៉ាងជ្រៅ ទៅក្នុងសកម្មភាពឧក្រិដ្ឋកម្មដែលត្រូវបានកំណត់ថាជាការបោសសម្អាតខ្មាំងផ្ទៃក្នុង ។ បន្ថែមលើនេះ ឌុច

បានទទួលស្គាល់ថា «នរណាម្នាក់ដែលបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា ជាខ្មាំងត្រូវតែកម្ទេចចោល ។ គ្មាននរណាម្នាក់អាចជំទាស់បានឡើយ» ។ ឌុច ខ្លាចក្រែងថា ខ្លួនគាត់ត្រូវបានដក ប្រសិនបើគាត់មិនចូលរួមអនុវត្តគោលនយោបាយរបស់បក្ស ។ «ខ្ញុំដឹងពីវិធីដែលត្រូវគ្រប់គ្រង និងការពារជីវិតរបស់ខ្ញុំ» ។ ឌុច បានចង្អុលបង្ហាញមនុស្សចំនួន ១០ នាក់ដែលចេញសេចក្តីសម្រេចថា នរណាមួយត្រូវយកទៅសម្លាប់ និងនរណាមួយត្រូវបានដោះលែង ។ ឈ្មោះអ្នកទាំងនោះរួមមាន ប៉ុល ពត, នួន ជា, តា ម៉ុក, សុន សេន, និង កែ ពក ។ ឌុច បានអះអាងថា គ្មាននរណាផ្សេងទៀតមានសិទ្ធិសម្រេចបែបនេះឡើយ ។

ឌុច បានអានបញ្ជីមួយដែលគួរឲ្យធុញទ្រាន់អំពីរចនាសម្ព័ន្ធដឹកនាំ (និងការផ្លាស់ប្តូរជាញឹកញាប់) នៅតាមភូមិភាគនីមួយៗក្នុងប្រទេសកម្ពុជា ដែលចង់សង្កត់ធ្ងន់ថា ខ្លួនមិនស្ថិតក្នុងឋានៈអ្នកដឹកនាំទាំងនោះឡើយ ។ ឌុច បានអះអាងថា ខ្លួនមិនអាចធ្វើអ្វីបានឡើយចំពោះគោលនយោបាយជាទូទៅក្នុងការ «កម្ទេច» នេះ ។ ឌុច បន្ថែមថា ប៉ុល ពត គឺជាឧក្រិដ្ឋជន ។ «ប៉ុល ពត ចង់ក្លាយជាស្តេច» ។ ចំណែកឯមន្ទីរ ស-២១វិញ ឌុច បានអះអាងថា វាគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ដែលជាអ្នកបញ្ជូនឯកសារចម្លើយសារភាពទាំងអស់ដែលមានចំណារទៅឲ្យ ប៉ុល ពត ធ្វើការសម្រេចចុងក្រោយ ។ មន្ទីរ ស-២១ មានលក្ខណៈពិសេសពីព្រោះសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានឃុំខ្លួន និងសម្លាប់នៅទីនោះ ។ ឌុច បាននិយាយថា «មនុស្សទាំងនេះគឺជាបន្លានៅក្នុងភ្នែករបស់ ប៉ុល ពត» ។ មនុស្សដែលត្រូវបានសម្លាប់នៅឯមន្ទីរសន្តិសុខចំនួន ១៩៥ ផ្សេងទៀត គឺសុទ្ធតែជា «មនុស្សស្មោះត្រង់ និងគ្មានទោសកំហុសអ្វីឡើយ» ។ ឌុច បាននិយាយថា ខ្លួននៅតែមានភាពរន្ធត់ ចំពោះអ្វីដែលបានកើតឡើងលើមនុស្សស្លូតត្រង់ទាំងអស់នោះ ។

ឌុច បាននិយាយថា ខ្លួនគាត់មានការទទួលខុសត្រូវ និងសូមទទួលកំហុសចំពោះឧក្រិដ្ឋកម្មនៅមន្ទីរស-២១ជារៀងរហូត ។ «ខ្ញុំសូមទទួលខុសត្រូវលើដួងវិញ្ញាណក្ខ័ណរបស់ប្រជាជនកម្ពុជាទាំងអស់ ដែលខ្ញុំបានសម្លាប់ ។ ខ្ញុំពិតជាមានវិប្បដិសារី និងសោកស្តាយយ៉ាងខ្លាំងចំពោះចំនួនមនុស្សស្លាប់ដែលស្ទើរមិនគួរឲ្យជឿបែបនេះ» ។ ឌុច បានបន្តទៀតថា «ខ្ញុំបានផុងខ្លួនបំរើឲ្យអង្គការឧក្រិដ្ឋ ។ ខ្ញុំមិនអាចដកខ្លួនចេញពីអង្គការនេះបានទេ ។ ខ្ញុំដូចជាឧបករណ៍តូចមួយនៅក្នុងកណ្តាប់ដៃរបស់បក្ស ។ ខ្ញុំពិតជាសោក ស្តាយ និងសូមទោសចំពោះដួងវិញ្ញាណក្ខ័ណរបស់អ្នកដែលស្លាប់ទៅ ។ ខ្ញុំពិតជាទទួលស្គាល់ឧក្រិដ្ឋកម្មទាំងអស់ដែលកើតមានឡើងនៅមន្ទីរស-២១ តាមផ្លូវច្បាប់ និងផ្លូវសីលធម៌» ។

ឌុច សង្ឃឹមថា ជនរងគ្រោះទាំងអស់នឹងបើកទ្វារចំហរសម្រាប់ការសុំទោសរបស់ខ្លួន ។ ឌុច អះអាងថា ខ្លួននឹងសហការយ៉ាងពេញទំហឹង និងស្មោះត្រង់នឹងតុលាការ រួមទាំងតុលាការយោធាផងដែលបានឃុំខ្លួនគាត់ជាលើកដំបូង ។ ឌុច ចង់ឲ្យមានការទទួលស្គាល់គាត់ថាជា មនុស្សម្នាក់នឹងគេឯងសារជាថ្មីម្តងទៀត ។

ឌុច បានបញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួនដោយអានឯកសារយោងទាំង ៣៤ ដោយមិនមានអំណះអំណាងបញ្ជាក់ប្រាប់អ្នកតាមដានស្តាប់សវនាការថា តើចំណុចណាមួយនៅក្នុងអត្ថបទដែលខ្លួនយោងសំដៅនោះ ។ វាគឺជាការបញ្ចប់ដ៏ចម្លែក ប៉ុន្តែវាក៏បានបង្ហាញថា ឌុច ពិតគឺជាគ្រូបង្រៀនម្នាក់ដែលយកចិត្តទុកដាក់លើសេចក្តីលម្អិត ។

## មេធាវីការពារក្តីលោក ការ សាវុត្ថ

មេធាវីការពារក្តីជាតិរបស់ ឌុច គឺលោក ការ សាវុត្ថ ធ្វើសេចក្តីថ្លែងការណ៍អស់រយៈពេលជិតបីម៉ោងឯណោះ ។ លោក កា សាវុធ បាននិយាយច្រំដែលៗ និងបង្ហាញនូវព័ត៌មានដែលលោកបានអះអាងថា គឺដើម្បីគាំទ្រមូលន័យជាទូទៅៈ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហម ហើយក៏មិនមែនជាជន ដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ដែលមានចែងដោយ (ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិដែលមាត្រា១ មានចែងអំពីលក្ខណៈវិនិច្ឆ័យលើយុត្តាធិការបុគ្គល) នោះដែរ ។

លោក ការសាវុត្ថ បានគូសបញ្ជាក់ថា មានមន្ទីរសន្តិសុខចំនួន ១៩៦ ហើយថានៅតាមស្រុកនីមួយៗមានរណ្តៅសាកសពជាច្រើនកន្លែង ។ លោកបានចោទសួរថា ហេតុអ្វីបានជាប្រធានគុកដទៃទៀត«រស់នៅដោយសុខស្រួលជាមួយនឹងគ្រួសាររបស់គេ» ខណៈពេលដែលកូនក្តីរបស់លោក គឺ ឌុច បែរជាត្រូវមកអង្គុយក្នុងក្រចកសេះធ្វើជាអ្នករងកំហុសជំនួសអ្នកដទៃទៅវិញ? លោកបន្តទៀតថា បើប្រៀបធៀបនឹងចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ នៅតាមមន្ទីរសន្តិសុខដទៃទៀតនោះ ឌុច បានសម្លាប់មនុស្ស២-៣នាក់ប៉ុណ្ណោះនៅឯមន្ទីរស-២១ ។ លោក ការ សាវុត្ថ បែរទៅនិយាយពីមូលន័យសារចុះសារឡើងនៅក្នុងសុន្ទរកថារបស់លោក ។

ជាមួយគ្នានេះដែរ លោក ការ សាវុត្ថ បានជំទាស់ទៅនឹងការពន្យាតអាជ្ញាយុកាល ១០ឆ្នាំ ដល់ ៣០ឆ្នាំ សម្រាប់ឧក្រិដ្ឋកម្មដែលបានចែងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដូចដែលមានចែងនៅក្នុងមាត្រា ៣ថ្មីនៃច្បាប់ អ.វ.ត.ក ។ លោកបាននិយាយថា ការពន្យាតអាជ្ញាយុកាលនេះបានរំលោភលើគោលការណ៍មិនប្រតិសកម្មក្នុងក្នុងច្បាប់អន្តរជាតិ ។ ដោយសារតែអង្គនីតិបញ្ញត្តិបានអនុម័តច្បាប់ អ.វ.ត.ក ដោយមានការពន្យាតអាជ្ញាយុកាល លោក ការ សាវុត្ថ បានអះអាងជាសំខាន់ពីភាពមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៃច្បាប់ (ឬមាត្រា ៣ថ្មី) ដោយអនុលោមតាមច្បាប់កម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីច្រានចោលការចោទប្រកាន់ពីបទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា៣ថ្មីប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។ បន្ទាប់មកទៀត លោក ការ សាវុត្ថ បានអះអាងថា ដូច្នេះ អង្គជំនុំជម្រះមិនអាចកាត់ទោស ឌុច បានទេ ប្រសិនបើយោងតាមច្បាប់កម្ពុជា ។

ទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាម) លោក ការ សាវុត្ថ បានពន្យល់ថា មានតែរដ្ឋាភិបាលទេដែលចេញសេចក្តីសម្រេចពីការធ្វើសង្គ្រាម ចំណែកឯ ឌុច គឺគ្រាន់តែជាអ្នកដែលគោរពតាមបញ្ជាតែប៉ុណ្ណោះ ។ បន្ថែមពីលើនេះ មានតែមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះដែលចេញបញ្ជា ហើយដូច្នេះ មេដឹកនាំទាំងនោះគឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់អំពើដែលចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ តាមទស្សនៈរបស់លោក ការ សាវុត្ថ ដោយសារតែ ឌុច មិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ឌុច មិនគួរត្រូវបានចោទប្រកាន់តាមច្បាប់ អ.វ.ត.ក ឡើយ ។ ឌុច មិនទទួលបានជោគជ័យតាមការព្យាយាមលើកឡើងពីយុត្តាធិការបុគ្គលក្រោមច្បាប់នេះ ដោយលោក ការ សាវុត្ថ ឡើយ ។ តាមទស្សនៈរបស់លោក មានតែបុគ្គលបីរូបប៉ុណ្ណោះដែលគួរតែត្រូវយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះ ពីព្រោះថា បុគ្គលបីរូបដែលនៅរស់រានមានជីវិតនេះ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលដែលមានចែងក្នុងមាត្រា១នៃច្បាប់ អ.វ.ត.កៈ នួន ជា, ខៀវ សំផន, និង អៀង សារី ។ លើសពីនេះទៀត មានតែបុគ្គលទាំងនេះទេដែលចេញបញ្ជាឲ្យចាប់ខ្លួន និង“កម្ទេច” ។ ឌុច ស្ថិតនៅលំដាប់ទីបីក្នុងចំណោមអ្នកទទួលបញ្ជា ។ ជាក់ស្តែង បុគ្គលខ្ពស់ជាងគេគឺ ប៉ុល ពត បន្ទាប់មក សុន សេន និងចុងក្រោយគឺ ឌុច ដែលធ្វើតាមបញ្ជារបស់ សុន សេន ។ លោក ការ សាវុត្ថ បានអះអាងបន្ថែមថា “បុគ្គលដែលទទួលបញ្ជា និងអនុវត្តតាមបញ្ជានោះ គឺមិនមែន“ជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត” នោះទេ ប្រសិនបើយោងតាមច្បាប់ អ.វ.ត.ក ។ លោកតែងតែវិលត្រឡប់ទៅរកមូលន័យនៃការទម្លាក់កំហុសដាក់អ្នកដទៃ ដោយនិយាយថា

ប្រធានគុកផ្សេងទៀតដែលបំរើការនៅក្នុងរបបខ្មែរក្រហម មានសិទ្ធិសេរីភាពរស់នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ហើយគួរតែនាំយកមកកាត់ទោសដែរ ប្រសិនបើកូនក្តីរបស់លោកត្រូវបានកាត់ទោសនោះ ។ លោកក៏បានបន្តទៀតថា ការប្រព្រឹត្តមិនស្មើភាពគ្នាបែបនេះ បានរំលោភលើបញ្ញត្តិសមភាពតាមមាត្រាទី៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

បើទោះបីជាលោកនិងកូនក្តីរបស់លោកបានទទួលស្គាល់នូវឧក្រិដ្ឋកម្មដែលកើតមានឡើងនៅមន្ទីរស-២១ (“ជីវិតស្លាប់មិនអាចយកចង្អេរមកបាំងបានទេ”) ក៏ដោយ លោក ការ សាវុត្ថ បញ្ជាក់ថា ឌុច មិនមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មទាំងនោះទេ ប្រសិនបើយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឬតាមច្បាប់ អ.វ.ត.ក ។ ជាមួយគ្នានេះដែរ លោក ការ សាវុត្ថ ក៏បានអះអាងថា ឌុច បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះដោយការបង្ខិតបង្ខំ ហើយម្យ៉ាងទៀត បើយោងតាមមាត្រា ២៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានចែងថា ប្រសិនបើជនណាម្នាក់ធ្វើតាមបញ្ជារបស់ថ្នាក់លើដោយការបង្ខិតបង្ខំនោះ ការកាត់ទោសអាចធ្វើឡើងតែចំពោះថ្នាក់លើប៉ុណ្ណោះ ។

លោក ការ សាវុត្ថ មិនបានយកចិត្តទុកដាក់លើបញ្ញត្តិផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ទេដូចជាការបដិសេធចំពោះការការពារដែលសំអាងលើការគោរពតាមបញ្ជាថ្នាក់លើ ដែលនេះគឺជាកត្តាមួយសម្រាប់ជួយសម្រាលទោសតែប៉ុណ្ណោះ ព្រមទាំងមិនបានយកចិត្តទុកដាក់ចំពោះការណ៍ដែលថានៅតាមមន្ទីរឃុំឃាំងផ្សេងទៀត គឺពុំមានកំណត់ហេតុគ្រប់គ្រាន់ដែលអាចធានាថា ការកាត់ទោសលើប្រធានគុកដែលនៅរស់រានមានជីវិតទាំងនោះ អាចនឹងប្រព្រឹត្តទៅដោគជ័យ ។ ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់អំពីមន្ទីរស-២១ ការយកចិត្តទុកដាក់អធិប្បាយយ៉ាងលម្អិតអំពីមន្ទីរស-២១របស់ ឌុច និងការប្រើប្រាស់ដែលមានលក្ខណៈជាប្រព័ន្ធ និងយង់ឃ្នងក្នុងការធ្វើទារុណកម្ម រួមទាំងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗទៀតក្នុងការទាញយកចម្លើយមុននឹងយកទៅសម្លាប់ ផ្តល់ជាមូលដ្ឋានដ៏សំខាន់សម្រាប់កាត់ទោស ឌុច ។ ជាមួយគ្នានេះ យើងក៏ត្រូវពិចារណាលើភស្តុតាងថ្មីៗដែលទាក់ទិននឹងអ្វីដែលបានកើតឡើងជាក់ស្តែងនៅគុកទួលស្លែង និងលើអ្នកដែលដឹកនាំពិតប្រាកដក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ។

លោក ការ សាវុត្ថ មិនបានពិចារណាពីគោលបំណងរបស់អ្នកចរចាក្នុងការបង្កើតច្បាប់ អ.វ.ត.ក ទាក់ទិននឹងវិសាលភាពនៃយុត្តាធិការលើបុគ្គលទេ ។ លោកបានផ្អែកការវិភាគទាំងស្រុងរបស់ខ្លួនលើអ្វីដែលមានក្នុងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទិននឹងការចេញបញ្ជាផ្សេងៗ ។ ការប្រព្រឹត្ត

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមក្នុងទ្រង់ទ្រាយធំដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ មិនអាចផ្អែក តែលើរបៀបដែលបក្សកុម្មុយនីស្តកម្ពុជាកំណត់ពីរចនាសម្ព័ន្ធដឹកនាំរបស់ខ្លួននៅលើក្រដាសឯកសារប៉ុណ្ណោះនោះទេ។ តាមពិត វាអាស្រ័យលើសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមទៅវិញទេ ដែលជាអ្នកកំណត់ថា អ្នកណាខ្លះដែលត្រូវចាត់ទុកជា «មេដឹកនាំជាន់ខ្ពស់» និង «អ្នកការទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មដែលបានកើតមានឡើង។ ដោយសារតែ ឌុច បានទទួលស្គាល់នូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១ សេចក្តីអះអាងរបស់លោក ការ សាវុត្ថ នៅថ្ងៃនេះ ពិតជាមានលក្ខណៈឆ្គាំឆ្គង ពីព្រោះលោកកំពុងតែព្យាយាមបដិសេធចំពោះពិរុទ្ធភាពទាំងឡាយ តាមច្បាប់ចំពោះអំពើរបស់ឌុច នៅមន្ទីរស-២១។ សហមេធាវីការពារក្តីអន្តរជាតិ ហ្វ្រង់ហ្វ័រ រូស្ស ប្រហែលជាគូសបញ្ជាក់បញ្ហាទាំងនេះបន្ថែមក្នុងអំឡុងពេលនៃការសួរដេញដោលចុងក្រោយរបស់លោកនៅព្រឹកថ្ងៃព្រហស្បតិ៍។